**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខ : ៣៣.០៧.ននអស

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៨

## ជម្រាបជូន

**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** : ស្តីពីអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រផ្នែកអក្សរសាស្ត្រចំនួន០២កន្លែង សិក្សារយៈពេល០៥ឆ្នាំ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

**យោង** : លិខិតលេខ ០៣៥សជណ.អល ចុះថ្ងៃព្រហស្បតិ៍ ៥កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ របស់អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវបានផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្ររយៈពេល០៥ឆ្នាំ ចំនួន០២កន្លែងជូនដល់មន្ត្រីរាជការក្រសួងមហាផ្ទៃ ដោយយោងទៅតាមខ្លឹមសារក្នុងចំណុចទី៧ នៃកំណត់ហេតុកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨។ អាហារូបករណ៍នេះមានគោលបំណងបង្កើនចំណេះដឹងផ្នែកអក្សរសាស្ត្រជូនដល់មន្ត្រីរាជការក្រសួងមហាផ្ទៃ និងដើម្បីពង្រឹងទំនាក់ទំនងលើវិស័យអប់រំរវាងកម្ពុជា-ឡាវ។

ចំពោះបេក្ខជនដែលមានបំណងចង់ចូលរួមសិក្សាថ្នាក់អាហារូបករណ៍ខាងលើត្រូវជូនដំណឹងទៅអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ឱ្យបានមុនថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។ ៣៤

**អគ្គនាយក**

ញ៉ាក់ សារឿន

<u>**សូមទំនាក់ទំនង៖**</u>

- លោកស្រី នី រតនា
- ទូរស័ព្ទលេខ: ០១៧ ៩៩០ ៩៩៤